# ចងការប្រាក់ពីប្រាក់តាក់ត្រូវបាន— កុំចោលប្រាក់តាក់ត្រូវបានរបស់អ្នក

**TAX REFUND LOANS – DON'T GIVE AWAY YOUR REFUND**

អ្នកធ្វើតាក់ខ្លះ ផ្តល់វិធីមួយដើម្បីឲ្យបានប្រាក់តាក់របស់អ្នកមកវិញឆាប់រហ័ស។ ទាំងនេះគឺចងការប្រាក់មួយរយៈខ្លី ដែលហៅថា Rapid Refunds ឬRefund Anticipation Loans (RALs)។ គេសន្យានឹងធ្វើឲ្យអ្នកបានទទួល ប្រាក់ក្នុងរយៈពីរបីថ្ងៃប៉ុណ្ណោះ។ មុនពេលអ្នកទទួល "ប្រាក់រហ័ស"របស់អ្នក អ្នកគួរដឹងអ្វីខ្លះៗដូចតទៅ:

អ្នកមិនបាច់ចងការប្រាក់ ដើម្បីធ្វើតាក់ឲ្យរួចរាល់ឡើយ។ អ្នកអាចទទួលការធ្វើតាក់ដោយមិនអស់ថ្លៃឡើយ។

ចងការប្រាក់តាក់មាន**ការប្រាក់និងឈ្នួលខ្ពស់ណាស់!** នេះគឺតម្លៃ 3 យ៉ាងដើម្បីទទួលចងការប្រាក់$1,500សំរាប់ រយៈពេល2អាទិត្យ:

| | |
|---|---|
| ឈ្នួលចងការប្រាក់ {Refund Loan (RAL) fees} | $75.00 |
| ការប្រាក់ប័ណ្ណក្រេឌីតយកការប្រាក់ (21%ភាគរយ) | $26.25 |
| ការខ្ចីប្រាក់ពីមិត្រ | $ 0 |



ប្រាក់តាក់ត្រូវបានកាន់តែច្រើន កំរៃឈ្នួលក៏កាន់តែខ្ពស់!!

បើអ្នកទទួលយកប្រាក់ចងការពីប្រាក់តាក់ អ្នកនឹងទទួលប្រាក់តាក់តិចជាង។

| | |
|---|---|
| ប្រាក់តាក់របស់អ្នកត្រូវបាន | $ 1,500.00 |
| ឈ្នួលធ្វើតាក់ | $ -100.00 |
| ឈ្នួលនិងការប្រាក់ពីការចងការប្រាក់តាក់ត្រូវបាន | $ - 75.00 |
| ចុងបញ្ចប់អ្នកទទួលបានតែ | $ 1,325.00 |

**អ្នកបានបង់ឲ្យគេ$75 សំរាប់ថ្លៃចងការ និង$100 សំរាប់ការជួលធ្វើតាក់ ដែលអ្នកអាចរកគេធ្វើដោយមិន អស់ថ្លៃ។**

ប្រាក់តាក់ដែលត្រូវទទួលរបស់អ្នក អាចត្រូវគេដកហូតយកទៅបង់ផ្តាច់បំណុលផ្សេងៗផងដែរ។ បើអ្នកជំពាក់ ប្រាក់ធនាគារមួយ ឬក្រុមហ៊ុនផ្សេងៗ ការចុះហត្ថលេខាលើក្រដាសបំណុលប្រាក់តាក់ដែលត្រូវទទួលនោះ អាច ធ្វើឲ្យអ្នកដើមបំណុលទាំងនោះយកប្រាក់តាក់ដែលត្រូវទទួលនោះ ដើម្បីបង់ផ្តាច់ប្រាក់ដែលអ្នកជំពាក់។ **ការចុះ ហត្ថលេខាលើក្រដាសបំណុល អាចធ្វើឲ្យអ្នកមិនបានទទួលប្រាក់តាក់នោះទាំងអស់តែម្តង!!**

ក្រសួងIRS ពិនិត្យក្រដាសធ្វើតាក់ខ្លះៗរៀងរាល់ឆ្នាំ។ បើគេត្រូវបានជ្រើសរើសយកក្រដាសតាក់របស់អ្នកមកឆែក ពិនិត្យ ប្រាក់តាក់ដែលត្រូវបានរបស់អ្នកនឹងត្រូវរក្សាទុកមួយរយៈដោយក្រសួង IRS។ ក្រុមហ៊ុនដែលឲ្យអ្នកខ្ចី ប្រាក់តាក់មុននោះ ក៏មិនត្រូវបានបង់ឲ្យដែរ រហូតដល់IRS បញ្ចប់ការពិនិត្យក្រដាសតាក់របស់អ្នករួចសិន។ ដូច្នេះ ក្រុមហ៊ុនដែលឲ្យខ្ចីប្រាក់មុននោះ និងទារការប្រាក់ច្រើនពីអ្នកទៀត។

**តើខ្ញុំត្រូវធ្វើរបៀបណាឲ្យបានប្រាក់តាក់ទាំងអស់ ឲ្យឆាប់ហើយមិនអស់កំរៃឈ្នួល?**

ត្រូវធ្វើតាក់ដោយ**មិនអស់ថ្លៃ**។ កន្លែងជំនួយធ្វើតាក់ដោយអ្នកស្ម័គ្រចិត្ត **(VITA)** មានបើកពាសពេញក្នុងរដ្ឋមិនីសូ តា ក្នុងរដូវធ្វើតាក់។ គេនឹងជួយធ្វើតាក់ដោយមិនយកកំរៃ។ កន្លែងខ្លះអាចធ្វើតាក់តាមកំព្យូទ័រ។ ដើម្បីរកកន្លែង VITA ដែលនៅជិតផ្ទះអ្នក សូមទូរស័ព្ទទៅយូណៃធិតវេ លេខ 211 ដែលនៅក្នុងរដ្ឋ ឬលេខ (651) 297-3724 ក្នុងតំបន់ទីក្រុងភ្លោះ។

សុំឲ្យក្រសួង IRS បញ្ជូនប្រាក់ពាក់ដែលត្រូវបានរបស់អ្នក ដាក់ចូលក្នុងគណនីរបស់អ្នកផ្ទាល់។ ប្រាក់ពាក់នោះនឹងចូលក្នុងគណនីរបស់អ្នកក្នុងរយៈ 2 អាទិត្យ បើអ្នកធ្វើពាក់តាមកំព្យូទ័រ ឬ 4 អាទិត្យបើអ្នកផ្ញើក្រដាសពាក់តាម ប៉ុស្តិ៍។ ប្រាក់ពាក់បានពីរដ្ឋត្រូវបានដាក់ចូលក្នុងគណនីរហ័សជាងនេះទៅទៀត!

## សូមបញ្ជាក់ថាអ្នកធ្វើពាក់ឲ្យអ្នក គោរពតាមបទបញ្ជាទាំងឡាយ

**អ្នកធ្វើពាក់ឲ្យ ដែលឲ្យខ្ចីប្រាក់(ទោះបីអ្នកមិនខ្ចីក៏ដោយ)ត្រូវតែ:**



- ធ្វើពាក់ឲ្យអ្នកបានត្រឹមត្រូវទាន់ពេល;
- បំពេញក្រដាសពាក់សព្វគ្រប់មុនសុំឲ្យអ្នកចុះហត្ថលេខាលើក្រដាសនោះ;
- គេក៏ត្រូវចុះហត្ថលេខាលើក្រដាសពាក់នោះ;
- ផ្តល់ឲ្យអ្នកនូវក្រដាសពាក់ថតចម្លងមួយច្បាប់;
- រក្សាក្រដាសពាក់ថតចម្លងរបស់អ្នកសំរាប់ 4 ឆ្នាំ;
- រក្សាពត៌មានរបស់អ្នកដោយសម្ងាត់;
- មានភាពស្មោះត្រង់អំពីសេវានិងតម្លៃរបស់គេ;
- ធ្វើពាក់ឲ្យអ្នក ទោះបីអ្នកមិនចង់បានប្រាក់ខ្ចីមុនក៏ដោយ;
- ដាក់តែចំនួនក្រេឌីត និងចំនួនកាត់បន្ថយប្រាក់ចំណូលណា ដែលអ្នកមានសិទ្ធិទទួលតែប៉ុណ្ណោះ;
- ផ្តល់ឲ្យអ្នកវិញនូវឯកសារទាំងឡាយ (ដូចជាក្រដាសW-2) ដែលអ្នកសុំយកមកវិញ; និង
- យកថ្លៃឈ្នួលស្មើមួយ **មិនមែន**យកតាមភាគរយនៃចំនួនប្រាក់ពាក់ដែលត្រូវបានឡើយ។

អ្នកធ្វើពាក់ណាដែលផ្តល់ឲ្យប្រាក់ចងការប្រាក់ពាក់ ត្រូវតែផ្តល់ឲ្យអ្នកនូវក្រដាសជូនដំណឹងមួយ បង្ហាញអំពីអត្រា ភាគរយប្រចាំឆ្នាំ (APR) នៃប្រាក់ចងការ ចំនួនដែលអ្នកត្រូវបានទទួលនិងត្រូវចុះថយ ហើយពេលវេលាដែលត្រូវ បានទទួលប្រាក់ពាក់ដោយមិនបាច់ខ្ចីបំណុល។ គេត្រូវប្រាប់អ្នកថា បើអ្នកនឹងត្រូវបង់ថ្លៃការប្រាក់ ក្នុងករណីដែល ប្រាក់ពាក់របស់អ្នកត្រូវបានពន្យារពេល។
**អ្នកនិងអ្នកធ្វើពាក់ត្រូវចុះហត្ថលេខាលើក្រដាសនេះ។**

អ្នកធ្វើពាក់ ត្រូវឲ្យអ្នកនូវវិក័យប័ត្រគត់អំពីអ្វីៗ និងថ្លៃដែលអ្នកត្រូវបង់ឲ្យ:

- ក្នុងការធ្វើពាក់;
- ការធ្វើពាក់តាមកំព្យូទ័រ; និង
- ប្រាក់ពាក់ដែលត្រូវខ្ចី (បើអ្នកបានខ្ចី)។

បើអ្នកធ្វើពាក់ឲ្យអ្នក មិនគោរពតាមបទបញ្ជាទាំងនេះ សូមរាយការណ៍ទៅក្រសួងពន្ធដាររដ្ឋមិនីសូតា (Minnesota Department of Revenue)។ អ្នកអាចនាំអ្នកទាំងនោះឡើងតុលាការ។ បើអ្នកឈ្នះក្នុងការប្តឹង អ្នកធ្វើពាក់នោះ ត្រូវបង់ថ្លៃមេធាវីឲ្យអ្នក។ បើអ្នកមានប្រាក់ចំណូលតិច សូមទូរស័ព្ទទៅ ជំនួយផ្នែកច្បាប់ (Legal Aid) លេខ (612) 334-5970 ឬ1-(800) 292-4150។

***Minneapolis Legal Aid – CLE***
*MN Legal Services Coalition*
*2324 University Avenue, Suite 101B*
*St. Paul, MN 55114*

***សូមកុំប្រើក្រដាសពត៌មាននេះបើក្រដាសនេះយូរជាងមួយឆ្នាំ។***
*សរសេរទៅយើងសុំក្រដាសថ្មីៗ បញ្ជីក្រដាសពត៌មាន ឬក្រដាស ផ្សេងៗ។ក្រដាសពត៌មានមិនមែនជាចម្លើយសព្វគ្រប់សំរាបញ្ហាច្បាប់ឡើយ។ សូមជួបជាមួយមេធាវីដើម្បីការសុំយោបល់។*

© 2011 Mid-Minnesota Legal Assistance. This document may be reproduced and used for non-commercial personal and educational purposes only. All other rights reserved. This notice must remain on all copies. Reproduction, distribution, and use for commercial purposes are strictly prohibited.